# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពត**

សំណុំរឿងរដ្ឋប្បវេណី
លេខ:៨២
ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២

**សាលក្រមរដ្ឋប្បវេណី**
**លេខ: ១២៦ ( គ )**
ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០២២ ។

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] **ជាចៅក្រមសាលាដំបូងខេត្តកំពត**

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] **ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពត**

**<u>គូភាគី:</u>**

-ដើមចោទឈ្មោះ [redacted] **ធី** ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ ១៩៧២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរលេខ[redacted] ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ មានអាសយដ្ឋានផ្ទះលេខ [redacted] ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] អត្តលេខ៨០៨ និងលោកមេធាវី [redacted] អត្តលេខ ២១០១និងលោកមេធាវី [redacted] អត្តលេខ ២៤៦១T ការិយាល័យ ក្រុមមេធាវី [redacted] នៃអគារ [redacted] ។

-ចុងចម្លើយឈ្មោះ [redacted] **លីណា** ភេទស្រី កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧១ ជនជាតិខ្មែរ កាន់អត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរលេខ[redacted] ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៣ អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ ៣០ ផ្លូវជ័យជំនះ ភូមិកំពង់បាយខាងជើង សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត ។

អ្នកតំណាងដោយអាណត្តិ គ្មាន ។

## អង្គហេតុ និង ចំណុចវិវាទ

កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ ប្ដីរបស់ដើមចោទឈ្មោះ [redacted] យីស៊ិន បានចុះកិច្ចសន្យាកក់ប្រាក់ទិញដីជាមួយម្ចាស់ដីឈ្មោះ [redacted] សោភ័ណ្ឌ និងបានប្រគល់ប្រាក់កក់ចំនួន ១០.០០០ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) ទៅឲ្យម្ចាស់ដីឈ្មោះ [redacted] សោភ័ណ្ឌ ដើម្បីទិញដី ០១កន្លែង ដែលមានតម្លៃសរុបចំនួន ១១៥.០០០ដុល្លារ ( ដប់មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) មានទីតាំងស្ថិតនៅភូមិទ្វីខាងត្បូង សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត សម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ 07080402-0770 ចំណែកឯប្រាក់ថ្លៃទិញដីដែលនៅសល់ចំនួន ១០៥.០០០ដុល្លារ ( ដប់ម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) ។

ក្រោយមក នៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៨ ប្ដីរបស់ដើមចោទ បានទិញដី០១កន្លែង ទៀត ពីឈ្មោះ [redacted] បូរ៉ានី (ម្ចាស់ដី) ដែលមានតម្លៃសរុបចំនួន ៩២.៥០០ដុល្លារ ( ប្រាំបួនម៉ឺនពីរពាន់ប្រាំរយដុល្លារអាមេរិក ) មានទីតាំងស្ថិតនៅ៖ ភូមិទ្វីខាងត្បូង សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត សម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ 07080402-0777 ។ បន្ទាប់មកទៀត នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ប្ដីរបស់កូនក្ដីយើងខ្ញុំ បានប្រគល់ប្រាក់សុទ្ធចំនួន ៣០.០០០ដុល្លារ ( បីម៉ឺនដុល្លារអាមេរិក ) ទៅឲ្យឈ្មោះ [redacted] ស៊ីធូ និង [redacted] សុគន្ធី ដើម្បីទិញដី ០១ កន្លែង ដែលមានទីតាំងស្ថិតនៅ៖ ភូមិទ្វីខាងត្បូង សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត សម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖07080402-0156 បន្ទាប់មក នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ ប្ដីរបស់កូនក្ដីយើងខ្ញុំ បានបង់ប្រាក់ថ្លៃដីខាងលើបន្ថែមចំនួន ២៤.០០០ដុល្លារ ( ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក ) ដោយសារតែប្ដីរបស់ដើមចោទមានការមមាញឹក និងជាប់រវល់ការងារនៅភ្នំពេញ ធ្វើឲ្យប្ដីរបស់ដើមចោទលំបាកក្នុងការធ្វើដំណើរឡើងចុះពីភ្នំពេញទៅកំពត ទើបគាត់ឲ្យឈ្មោះ [redacted] លីណា ដែលត្រូវជាប្អូនស្រីបង្កើតរបស់គាត់ឈរឈ្មោះនៅលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ( ដី ) ទាំង ០៣ កន្លែង ខាងលើនោះ ជំនួសគាត់ ម្យ៉ាងទៀត ឈ្មោះ [redacted] លីណា មានទីលំនៅ និងរស់នៅខេត្តកំពតស្រាប់ ងាយស្រួលក្នុងការមើលថែរក្សាគ្រប់គ្រងដីខាងលើផង ។ ក្រោយមកនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ប្ដីរបស់ដើមចោទបានទទួលមរណភាព ដោយសារជំងឺ កូវីត១៩ ។ ក្រោយពីប្ដីបានទទួលមរណភាព ដើមចោទបានព្យាយាមទំនាក់ទំនងជាច្រើនលើកច្រើនសារជាមួយចុងចម្លើយ ដើម្បីសួរនាំអំពីដីខាងលើ ប៉ុន្តែចុងចម្លើយ មិនបានផ្ដល់ព័ត៌មាន ឬប្រាប់ពីទីតាំងដីខាងលើនោះ មកដើមចោទឡើយ និងបានប្រាប់ថាមិនមានដីធ្លីនៅខេត្តកំពតនោះទេ ទើបធ្វើឱ្យដើមចោទដាក់ពាក្យបណ្ដឹងទាមទារដីពីចុងចម្លើយតែម្ដង ។

### ១.ការទាមទាររបស់ដើមចោទ

-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] លីណា ផ្ទេរកម្មសិទ្ធិដីចំនួនបីកន្លែងមកក្រោមឈ្មោះ [redacted] សូលី ដែលត្រូវជាកូនស្រីបង្កើតរបស់ឈ្មោះ [redacted] យីស៊ិន ដែលបានទទួលមរណភាព ដែលមានទីតាំងស្ថិតនៅ ភូមិទ្វីខាងត្បូង សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដូចខាងក្រោម៖

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ 07080402-0777 ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖07080402-0770 ចុះថ្ងៃទី០៦ខែធ្នូឆ្នាំ២០១៩ និង

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ 07080402-0156 ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ។



Scanned with CamScanner

-បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់មកឲ្យដើមចោទចំនួន ២០.០០០ដុល្លារ ( **ពីរម៉ឺនដុល្លារអាមេរិក** ) ជាប្រាក់សំណង ជំងឺចិត្ត និងប្រាក់ថ្លៃសេវាមេធាវី ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២.សេចក្តីថ្លែងការណ៍របស់គូភាគី**

-ដើមចោទឈ្មោះ [redacted] ធី បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ប្តីខ្ញុំត្រូវជាបងបង្កើតរបស់ចុងចម្លើយ ហើយប្តីខ្ញុំស្លាប់ដោយជំងឺកូវីត១៩ ។ មុនពេលប្តីខ្ញុំស្លាប់គាត់បានឲ្យលុយទៅចុងចម្លើយទិញដី ៣ កន្លែង គឺ៖ ១-ក្បាលដីលេខ ០៧៧៧ ចុះថ្ងៃទី០៦-១២-២០១៩, ២-ក្បាលដីលេខ ០៧៧០ ចុះថ្ងៃទី០៦-១២-២០១៩, ៣-ក្បាលដីលេខ០១៥៦ ចុះថ្ងៃទី ០៦-១២-២០១៩ ។

ក្រោយពេលធ្វើបុណ្យឲ្យសពប្តីរួច ខ្ញុំបាន ព្យាយាមទំនាក់ទំនងទៅចុងចម្លើយជាច្រើនលើកច្រើនសារ ដើម្បីសួរនាំអំពីដីខាងលើ ប៉ុន្តែឈ្មោះ [redacted] លីណា មិនបានផ្តល់ព័ត៌មាន ឬប្រាប់ពីទីតាំងដីខាងលើនោះ មកខ្ញុំទេ ហើយគាត់បាននិយាយប្រាប់ថា មិនមានដីធ្លីរបស់ស្វាមីខ្ញុំនៅខេត្តកំពតនោះទេ ដោយម្តងនិយាយថាចេះ ថ្ងៃស្អែកនិយាយផ្សេង ម្តងថាទិញចូលគ្នាពាក់កណ្តាលម្នាក់ ហើយខ្ញុំបានព្យាយាមនិយាយសម្រួលជាមួយគ្នានៅផ្ទះខ្ញុំ ឲ្យគាត់ប្រគល់សិទ្ធិឲ្យទៅកូនខ្ញុំវិញ តែគាត់អត់ព្រម ពេលនេះខ្ញុំសុំឲ្យមេធាវីរបស់ខ្ញុំជាអ្នកថ្លែងការណ៍ជំនួសខ្ញុំ ។

លោកមេធាវី [redacted] បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ថាៈ ខ្ញុំចង់ថ្លែងការបន្ថែមលើអង្គហេតុថា ពេលប្តីរបស់កូនក្តីខ្ញុំនៅរស់ គាត់ជាប់រវល់ការងារច្រើននៅភ្នំពេញ ហើយចុងចម្លើយដែលត្រូវជាប្អូនគាត់មានទីលំនៅ នៅកំពតស្រាប់ហើយនៅលីវ ទើបប្តីកូនក្តីខ្ញុំប្រគល់ឲ្យប្អូនធ្វើប្លង់ដាក់ឈ្មោះប្អូនទាំងបីកន្លែង ។ ក្រោយពេលប្តីគាត់បានទទួលមរណភាព កូនក្តីខ្ញុំក៏បានព្យាយាមទំនាក់ទំនងទៅចុងចម្លើយជាច្រើនលើនច្រើនសារ ដើម្បីសួរនាំអំពីដីខាងលើ ប៉ុន្តែឈ្មោះ [redacted] លីណា មិនបានផ្តល់ព័ត៌មាន ឬប្រាប់ពីទីតាំងដីខាងលើនោះមកកូនក្តីខ្ញុំឡើយ និងបាននិយាយទៀតថា អត់មានដីរបស់ប្តីកូនក្តីខ្ញុំនៅកំពតទេ ។ ដោយមូលហេតុខាងលើនេះហើយ ទើបកូនក្តីខ្ញុំប្តឹងទាមទារឲ្យចុងចម្លើយ ផ្ទេរកម្មសិទ្ធិដីចំនួន៣ កន្លែងនោះមកឲ្យឈ្មោះ [redacted] សូលី ដែលត្រូវជាកូនបង្កើតរបស់ឈ្មោះ [redacted] ឃីស៊ុន ដែលបានទទួលមរណភាពកាលពីថ្ងៃទី១២-៤-២០២១ តែខាងចុងចម្លើយគេមិនព្រម ។ ចំពោះដីទី១ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៧០៨០៤០២-០៧៧០ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ទិញតម្លៃ ១១៥.០០០ ( ដប់មួយម៉ឺនប្រាំពាន់ ) ដុល្លារអាមេរិក កាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ ទិញពីឈ្មោះ [redacted] សោភណ្ឌ័ បានកក់ ១០.០០០ ( មួយម៉ឺន ) ដុល្លាអាមេរិក បង់ផ្តាច់លើកទី២ តាមធនាគារមេហ្គា, ដី០៧៧៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ទិញតម្លៃ ៩២.៥០០( ប្រាំបួនម៉ឺនពីរពាន់ប្រាំរយ ) ដុល្លារអាមេរិក កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ទិញពីឈ្មោះ [redacted] ប៉ូរ៉ានី បានបង់ប្រាក់តាមការវេលុយចូលធនាគារ [redacted] មានលេខកូតប្រតិបត្តិការលេខ ៦៩៨០២២០៩០ ចុះថ្ងៃទី១១-៧-២០១៨ ដែលជាគណនីរួមគ្នារវាងឈ្មោះ [redacted] ឃីស៊ុន និង [redacted] លីណា , ក្បាលដីលេខ០១៥៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ទិញតម្លៃ៥៤.០០០ ( ប្រាំម៉ឺនបួនពាន់ ) ដុល្លារអាមេរិក កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ទិញពីឈ្មោះ [redacted] ស៊ីធូ និង [redacted] សុគន្ធី បានបង់ប្រាក់សុទ្ធចំនួន ៣០.០០០ ( បីម៉ឺន ) ដុល្លា ហើយបង់លើកទី២ ចំនួន២៤.០០០ ( ពីរម៉ឺនបួនពាន់ )

ដុល្លាអាមេរិក តាមធនាគារ[redacted] កូនក្ដីខ្ញុំមានភស្តុតាងទាំងអស់ ខ្ញុំបានដាក់ជូនតុលាការរួចអស់ហើយ ។ ក្នុងរឿងនេះដែរខ្ញុំបាទសំណូមពរដូចមាននៅក្នុងសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី ១៣-៥-២០២២ ដដែល ។

-ចុងចម្លើយឈ្មោះ [redacted] លីណា បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា: ខ្ញុំមានកុងធនាគារប្រើរួមគ្នា បើខ្ញុំអត់មានលុយ ហេតុអីបានបងខ្ញុំឲ្យខ្ញុំធ្វើប្លង់ដាក់ឈ្មោះខ្ញុំធ្វើអី ? ខ្ញុំមានប្លង់ដាក់ឈ្មោះខ្ញុំ លុយរកស៊ីទិញដីជាមួយគ្នាតែ ២ កន្លែងទេ គឺក្បាលដីលេខ០៧៧០, ០៧៧៧ ចំណែកក្បាលដីលេខ០១៥៦ ជាដីរបស់ខ្ញុំទិញតែម្នាក់ឯងទេ ។ ក្បាលដីលេខ០៧៧៧ តម្លៃ ៩២.៥០០ ( ប្រាំបួនម៉ឺនពីរពាន់ប្រាំរយ ) ដុល្លារអាមេរិក ទិញចូលគ្នា៣ នាក់ បងស្រីខ្ញុំឈ្មោះ[redacted]សាន ចេញ ៣០.០០០( បីម៉ឺន ) ដុល្លារ ខ្ញុំចេញ ៣០.០០០ ( បីម៉ឺន ) ដុល្លារ សល់ប៉ុន្មានបងប្រុសជាអ្នកចេញ, ក្បាលដីលេខ០៧៧០ តម្លៃ ទិញតម្លៃ១១៥.០០០ ( មួយសែនមួយម៉ឺនប្រាំពាន់ ) ដុល្លារអាមេរិក ទិញចូលគ្នា ៣ នាក់ បងស្រីខ្ញុំឈ្មោះ[redacted]សាន ចេញ២០.០០០ ( ពីរម៉ឺន ) ដុល្លា ខ្ញុំចេញ ២០.០០០ ( ពីរម៉ឺន ) ដុល្លារ សល់ប៉ុន្មានបងប្រុសជាអ្នកចេញ ។ ចំណែកក្បាលដីលេខលេខ០១៥៦ ទិញតម្លៃ៥៣.០០០ ( ប្រាំម៉ឺនបីពាន់ )-ដុល្លារ ទិញពីឈ្មោះ [redacted] ស៊ីធូ ។ ដីទាំងបីកន្លែង ទិញក្នុងឆ្នាំ២០១៨ ដូចគ្នា តែដីលេខ០៧៧០ ទិញមុនគេ បន្ទាប់មកទិញក្បាលដីលេខ ០៧៧៧ ដីលេខ០១៥៦ ទិញក្រោយគេ ហើយដីលេខ០១៥៦ ជាដីកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំម្នាក់ឯងទេ ។ ពេលទិញដីនេះខ្ញុំបានទៅប្រគល់លុយឲ្យគេ ហើយបានផ្ដិតមេដៃផងដែរ តែខ្ញុំអត់ចាំបានថា អ្នកដែលនាំទៅនោះមានអ្នកណាខ្លះនោះទេ ។ ប្លង់ទាំងបីគឺឈ្មោះខ្ញុំទាំងអស់ ព្រោះបងខ្ញុំគាត់នៅភ្នំពេញ ជាប់រវល់ការងារច្រើន ហើយកន្លងមកគាត់ទិញដីគេ គាត់តែងតែដាក់ឈ្មោះខ្ញុំរហូត មិនបានដាក់ឈ្មោះ[redacted]សាន ទេ ដោយសាបងស្រីមានប្ដី និងមានចុះសំបុត្រអាពាហ៍ពិពាហ៍ ។ កន្លងមកគឺធ្លាប់បានចចារគ្នាជាមួយដើមចោទមែន គាត់ថាឲ្យខ្ញុំផ្ទេរឈ្មោះឲ្យកូនគាត់ ពេលនោះខ្ញុំបានប្រាប់គាត់វិញថាដាក់អត់កើតទេ ព្រោះដីនោះទិញចូលគ្នា ទុកលក់ចំណេញចែកគ្នា ។ ពេលទិញដី០៧៧៧ ខ្ញុំក៏បានទៅទិញជាមួយបងខ្ញុំដែរ ថែមទាំងបានតថ្លៃជាមួយគ្នាទៀតផង តម្លៃត្រូវគ្នាគឺ ៩២.៥០០ ( ប្រាំបួនម៉ឺនពីរពាន់ប្រាំរយ ) ដុល្លាអាមេរិក ហើយខ្ញុំក៏បានទៅប្រគល់ជាមួយបងខ្ញុំដែរ នៅធនាគារ គឺប្រគល់លុយសុទ្ធ ប្រគល់ទាំងអស់តែម្ដង បងខ្ញុំស្លាប់ក្នុងឆ្នាំ២០២១ ហើយប្លង់ធ្វើក្នុងឆ្នាំ ២០១៨ ។ ចំពោះដីលេខ០៧៧០ តម្លៃ១១៥.០០០ (ដប់មួយម៉ឺនប្រាំពាន់ ) ដុល្លារអាមេរិក ទិញពីឈ្មោះអត់ស្គាល់ ពេលប្រគល់លុយ គឺខ្ញុំអត់បានទៅប្រគល់ជាមួយបងទេ និងដីលេខ០១៥៦ ខ្ញុំទិញពីឈ្មោះ [redacted] ស៊ីធូ ទិញតែម្នាក់ឯងទេ តែពេលប្រគល់លុយ គឺខ្ញុំទៅជាមួយបងប្រុស ពេលនោះមានតែអ្នកលក់ដីទេ ដែលទៅទទួលលុយ តែខ្ញុំអត់មានឯកសារប្រគល់លុយទេ ហើយខ្ញុំក៏មិនបានដឹងថាបងប្រុសខ្ញុំបានប្រគល់លុយឬអត់ទេ ខ្ញុំមិនចាប់អារម្មណ៍ ។ ពេលនោះបានផ្ដិតមេដៃទិញ-លក់ តែមិនដឹងថាបងប្រុសខ្ញុំបានផ្ដិតមេដៃដែរឬអត់ទេ ។ ហើយឯកសារនោះ បងប្រុសជាអ្នកទុក ខ្ញុំអត់បានទុកឯកសារនោះ ព្រោះយល់ថាវាមិនសំខាន់ទេ ពេលនេះខ្ញុំមានភស្តុតាងតែប្លង់ទេ ។

-លោកមេធាវី [redacted] បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ថា៖ សុំច្រានចោលនូវរាល់ការថ្លែងការណ៍របស់ចុងចម្លើយទាំងអស់ ព្រោះចុងចម្លើយមិនមានភស្តុតាងណាមួយគួរឲ្យតុលាការជឿបានទេ ។ ចំណែកកូនក្ដីខ្ញុំមានភស្តុតាងគ្រប់គ្រាន់ ហើយបានយកមកដាក់ជូនតុលាការរួចអស់ហើយ និងមានសាក្សីឈ្មោះ[redacted]ចាន់មករា ដែលគាត់បានថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ហើយខ្ញុំក៏បានដាក់ជូនតុលាការរួចហើយដែរ និងមានសាក្សីដែលជាអ្នកលក់ដីនិងនាំកូនក្ដីខ្ញុំទិញដីទៀតផង ។

-សាក្សីឈ្មោះ [redacted] ចាន់មករា បានឆ្លើយបំភ្លឺថា៖ ខ្ញុំជាជំនួយការរបស់លោកមេធាវី ពេលដើមចោទសួរទៅចុងចម្លើយមុនដំបូង ចុងចម្លើយឆ្លើយថា ដីនេះទិញចូលគ្នា២នាក់ប្ដីរបស់ដើមចោទ ម្នាក់ពាក់កណ្ដាល ដីនោះមាន៣ កន្លែង



Scanned with CamScanner

រំលែងបាន២-៣ ថ្ងៃក្រោយមក ចុងចម្លើយឆ្លើយថា មិនមែនទិញចូលគ្នាតែ២ នាក់នោះទេ គឺទិញចូលគ្នា៣ នាក់បងស្រីម្នាក់ទៀតឈ្មោះ [redacted] សាន ។

-ចុងចម្លើយឈ្មោះ [redacted] លីណា បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ពីមុនធ្លាប់មានការចចារគ្នា ដូចចម្លើយសាក្សីបានឆ្លើយមែន គឺមុនដំបូងខ្ញុំឆ្លើយថាទិញហ៊ុនគ្នាមែន តែខ្ញុំមិនបានឆ្លើយថាទិញចូលគ្នា២នាក់នោះទេ ខ្ញុំគ្រាន់តែបានឆ្លើយថាទិញចូលគ្នា ព្រោះពេលនោះដើមចោទ មិនបានសួរខ្ញុំថា ទិញចូលគ្នាប៉ុន្មាននាក់នោះទេ ។

-សាក្សីឈ្មោះ [redacted] សារ៉ាត់ បានឆ្លើយបំភ្លឺថា៖ ខ្ញុំជាអ្នកគួកចេដីឱ្យឈ្មោះ [redacted] យីស៊ុន ខ្ញុំធ្លាប់ស្គាល់ប្តីរបស់ដើមចោទឈ្មោះ [redacted] យីស៊ុន ហើយក៏ធ្លាប់ស្គាល់ចុងចម្លើយដែរ ។ ខ្ញុំស្គាល់គាត់មុនដំបូង គឺគាត់មកកំពតរកទិញដី ហើយខ្ញុំបាននាំគាត់ឲ្យទិញដី១កន្លែងនៅភូមិទី្វខាងត្បូង ទិញពីឈ្មោះ [redacted] សោភណ្ឌ័ ជាមួយមិត្តភក្ត្រខ្ញុំពីរនាក់ទៀត តម្លៃ ១១៥.០០០ (ដប់មួយម៉ឺនប្រាំពាន់ ) ដុល្លារអាមេរិក ហើយកក់មុន តម្លៃ១០.០០០ ( មួយម៉ឺន ) ដុល្លារអាមេរិក ពេលនោះខ្ញុំអត់បានចូលរួមទេ តែឈ្មោះ [redacted] យីស៊ុន គាត់បានតែប្រាប់ខ្ញុំ ។ រាល់ពេលទិញដី គឺចុងចម្លើយអត់បានចូលរួមទិញទេ ព្រោះខ្ញុំអត់ដែលបានឃើញគាត់ទេ ។ ខ្ញុំជាអ្នកគួកចេដី ហើយខ្ញុំធ្លាប់នាំឈ្មោះ [redacted] យីស៊ុន ទិញដីបាន២កន្លែង គឺដីមួយកន្លែង និងផ្ទះ១កន្លែង ។ ពេលនាំគាត់ទិញដីមុនដំបូង គឺមេជាងខ្ញុំបានណែនាំឲ្យគាត់ទិញ ហើយគាត់និយាយថា ចាំគាត់ឲ្យលុយចាយ ។ ខ្ញុំធ្លាប់ជួបជាមួយ [redacted] លីណា តែម្តងទេ គឺជួបក្រោយពេលខ្ញុំនាំឈ្មោះ [redacted] យីស៊ុន ទៅទិញផ្ទះរបស់ឈ្មោះ [redacted] ស៊ីធួ រួច ថ្ងៃនោះឃើញគាត់ទៅមើលផ្ទះនោះដែរ ។ ចំណែកក្បាលដីលេខ ០១៥៦ ខ្ញុំ និង មេភូមិ ក៏បានណែនាំ [redacted] យីស៊ុន ដែរ តម្លៃ ៥០.០០០ ( ប្រាំម៉ឺន ) ដុល្លា ជាង កក់មុន ៦.០០០ ( ប្រាំមួយពាន់ ) ពេលនោះខ្ញុំបានចូលធ្វើជាសាក្សីដឹងឮ ថ្ងៃនោះមានឈ្មោះ ខ្ញុំ , [redacted] ប៊ិន, [redacted] ហ៊ិន នៅទីនោះដែរ ហើយអ្នកប្រគល់លុយគឺ ប្តីរបស់ដើមចោទមិនមែនឈ្មោះ [redacted] លីណា ទេ ព្រោះថ្ងៃនោះ [redacted] លីណា អត់បានចូលរួមទេ ។

-ចុងចម្លើយឈ្មោះ [redacted] លីណា បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា: កុងធនាគារ [redacted] បើកក្នុងឆ្នាំ២០១៥ អត់សូវចាំច្បាស់ទេ ឬមួយក្នុងឆ្នាំ ២០១៧ ក៏មិនដឹង គឺបើកសំរាប់ទិញលក់ដីជាមួយគ្នា ។ សព្វថ្ងៃខ្ញុំនៅផ្ទះអត់ធ្វើការអីទេ តែពីមុនខ្ញុំធ្វើការបកប្រែភាសាចិន នៅរោងចក្រ បានប្រាក់ខែក្នុង១ ខែ៥០០ ( ប្រាំរយ ) ដុល្លា ហើយពេលនោះ ខ្ញុំអត់ទាន់មានប្តីទេ ខ្ញុំធ្វើការតាំងពីឆ្នាំ២០០០ មកនិងចងការប្រាក់ឲ្យកម្មកររោងចក្រផង ។ ដីលេខ ០១៥៦ គឺជាដីដែលខ្ញុំទិញតែម្នាក់ឯងមែន តែខ្ញុំអត់មានឯកសារជាភស្តុតាងទេ មិនដឹងថាបងប្រុសទុកនៅជាមួយប្រពន្ធឬអត់ ។

-លោកមេធាវី [redacted] បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ កន្លងមកកូនក្តីខ្ញុំទិញដីតែងតែធ្វើប្លង់ដាក់ឈ្មោះឲ្យប្អូនស្រីរហូត ព្រោះគាត់នៅភ្នំពេញ មិនងាយធ្វើដំណើរចុះឡើងទេ មួយទៀតដោយគិតថាប្អូនស្រីនៅលីវ ហើយនៅក្នុងខេត្តកំពតស្រាប់ ។ ដោយសារកូនក្តីខ្ញុំស្លាប់ ទើបចុងចម្លើយមានឱកាសបន្លំយកតែម្តង ។

-ចុងចម្លើយឈ្មោះ [redacted] លីណា បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ចំពោះដីលេខ ០៧៧៧, ០៧៧០ ពិតជាបានទិញចូលគ្នា ៣នាក់មែន ។ ពេលទិញដី គឺខ្ញុំអត់សូវចេះមើលដីថាល្អឬអាក្រក់ទេ ព្រោះបងប្រុសខ្ញុំគាត់មានបទពិសោធ តាំងពីគាត់នៅកំលោះមក ខ្ញុំបានចូលរួមលុយឲ្យគាត់នៅផ្ទះ ក្រោយពេលប្រគល់ឲ្យគាត់ហើយ គាត់ក៏បានយកលុយនោះទៅដាក់ធនាគារ ។ កន្លងមកខ្ញុំអត់បានទុកលុយនៅផ្ទះទេ គឺខ្ញុំបានទៅដកពីធនាគារ រួចហើយយកមកប្រគល់ឲ្យគាត់នៅផ្ទះ ។ ថ្ងៃនោះបងស្រីខ្ញុំអត់បានដកលុយពីធនាគារទេ ព្រោះគាត់ទុកលុយនៅផ្ទះ ។

រាល់ពេលទិញដីម្តងៗគឺបងប្រុសខ្ញុំជាអ្នកសម្រេច ។ ដីលេខ០១៥៦ ខ្ញុំជាអ្នកទិញ តែខ្ញុំអត់បានទៅមើលដីនោះទេ ខ្ញុំឲ្យបងប្រុសជួយមើលឲ្យ ហើយពេលប្រគល់លុយ គឺខ្ញុំប្រគល់តាមធនាគារ[redacted] ប្រគល់លុយឲ្យតែមួយលើកទេ ដីនោះទទឹងដូចជា៤ ម៉ែត្រជាង ។ ហើយរឿងមួយទៀត ដែលថា៥០ % នោះ ខ្ញុំមិនហ៊ានសម្រេចចិត្តបាននោះទេ ទើបខ្ញុំឆ្លើយថា ចាំទៅផ្ទះពិចារណាសិន ។ ដីទាំងបីកន្លែងនោះ ទិញក្នុងឆ្នាំ ២០១៨ អំឡុងពេលនោះ គឺខ្ញុំនៅភ្នំពេញបន្ទប់ជួល ក្នុង ១ ខែ ៥០ ( ហាសិប ) ដុល្លា ពេលនោះខ្ញុំធ្វើការជាអ្នកបកប្រែភាសារចិន ខ្ញុំរកចំណូលបានក្នុង១ ខែជិត ១.០០០ ( មួយពាន់ ) ដុល្លា គឺខ្ញុំមានភាគហ៊ុនទិញដីជាមួយតាំងពីមុនមកម្លេះ ។ ក្រោយពេលបងប្រុសខ្ញុំស្លាប់ គឺដើមចោទបានតេមកខ្ញុំ គាត់ចង់ឲ្យខ្ញុំផ្ទេរសិទ្ធិទៅឲ្យកូនគាត់ ហើយខ្ញុំក៏បានឆ្លើយថា បើគាត់ជួយចេញលុយថ្លៃដើមពាក់កណ្តាលមកឲ្យខ្ញុំ ទើបខ្ញុំយល់ព្រមមែន ក្រោយមកខ្ញុំក៏បានឆ្លើយថា ចាំគិតមើលសិនមែន ។

-ដើមចោទឈ្មោះ [redacted] ធី បានថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្ញុំមានឯកសារឡូលដីលេខ០៧៧៧ ទិញរួមគ្នា តែ ២កន្លែងទៀតគឺក្បាលដីលេខ០៧៧០ និង០១៥៦ ( ផ្ទះ ) គឺជាដីដែលប្តីខ្ញុំទិញតែម្នាក់ឯងទេ អត់មានចូលគ្នាទេ ខ្ញុំអត់ឯកភាពទេ ។

-ចុងចម្លើយឈ្មោះ [redacted] លីណា ថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ក្រោយពេលខ្ញុំបានទិញដីនេះរួចហើយ ខ្ញុំក៏បានឲ្យលុយទៅបងប្រុសរបស់ខ្ញុំចំនួន១០.០០០ ( មួយម៉ឺន ) ដុល្លារ ដើម្បីយកទៅកក់ឲ្យគេ ។ ខ្ញុំពិតជាធ្លាប់បានទៅដកលុយជាមួយបងប្រុសខ្ញុំចំនួនជាង៤០.០០០ ( ជាងបួនម៉ឺន ) ដុល្លាមែន ដូចជា៤២.០០០ ( បួនម៉ឺនពីរពាន់ ) តែលុយនោះបងប្រុសខ្ញុំជាអ្នកកាន់ ។ ខ្ញុំមិនបានដឹងថាបងប្រុសខ្ញុំឲ្យគេប៉ុន្មាននោះទេ ថ្ងៃនោះខ្ញុំក៏នៅទីនោះដែរ គ្រាន់តែមិនបានចាប់អារម្មណ៍ ។ ក្រោយពេលបងប្រុសខ្ញុំស្លាប់ ខ្ញុំក៏ធ្លាប់សម្រួលជាមួយដើមចោទដែរ ពេលនោះខ្ញុំថាសុំយកតែប្រាក់ដើមរបស់បងស្រីចំនួនតែ ៣០.០០០( បីម៉ឺន ) ដុល្លារមែន ហើយចំណែករបស់ខ្ញុំ គឺខ្ញុំមិនយកទេ តែពេលនេះដើមចោទបានប្តឹងខ្ញុំហើយ ខ្ញុំមិនព្រមទទួលយក៣០.០០០ ( បីម៉ឺន ) ដុល្លានោះទេ ខ្ញុំនៅតែសុំលក់ដី ហើយចែកគ្នា ៣ ចំណែកដដែល ។

-ដើមចោទឈ្មោះ[redacted] ធី ថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ពេលនេះខ្ញុំយល់ព្រមឲ្យទៅឈ្មោះ[redacted]សាន ចំនួន ២០.០០០ ( ពីរម៉ឺន ) ដុល្លារ ចំណែកចុងចម្លើយឈ្មោះ[redacted]លីណា ខ្ញុំមិនឲ្យទេ ។

មេធាវីធ្វើសេចក្តីសន្និដ្ឋានថា៖ ពាក់ពន្ធ័នឹងរឿងនេះដែរ ចុងចម្លើយបានឆ្លើយថា ដីទិញចូលហ៊ុនគ្នា៣ នាក់ គឺក្បាលដីលេខ ០៧៧៧ និង ០៧៧០ ចំណែកក្បាលដីលេខ ០១៥៦ គឺជាដីដែលខ្លួនបានទិញតែម្នាក់ឯងទេ តែអត់ឯកសារអីជាភស្តុតាងទេ ។ សំខាន់បើក្បាលដីលេខ០១៥៦ បើគាត់ជាម្ចាស់ដី គឺគាត់អាចឆ្លើយស៊ីសង្វាក់គ្នានឹងម្ចាស់ដីដើមបាត់ហើយ ។ ដូច្នេះចម្លើយគាត់អត់ពិតទេ មួយទៀតពាក់ពន្ធ័នឹងកុងរួមគ្នា ក៏ចុងចម្លើយគ្មានភស្តុតាង ដើម្បីយកមកដាក់ជូនតុលាការដែរ សូមលោកស្រីចៅក្រម មេត្តាពិនិត្យ និងពិចារណា ។ ចំពោះក្បាលដីលេខ០៧៧០ និង០១៥៦ គឺជាដីរបស់កូនក្តីខ្ញុំសុទ្ធសាធ ព្រោះចុងចម្លើយអត់មានភស្តុតាងអ្វីយកមកដាក់ជូនតុលាការទេ ចំណែកកូនក្តីខ្ញុំ មានភស្តុតាងគ្រប់គ្រាន់ ហើយក៏បានដាក់ជូនតុលាការ ដើម្បីពិនិត្យរួចអស់ហើយដែរ សូមលោកស្រីចៅក្រមមេត្តាពិនិត្យ និងពិចារណា សម្រេចតាមពាក្យបណ្តឹង ចុះថ្ងៃទី២៨-០២-២០២២ ដដែល និងសុំធ្វើសេចក្តីសន្និដ្ឋានតាមសេចក្តីថ្លែងការណ៍ចុះថ្ងៃទី១៣-៥-២០២២ ទុកដដែល ។



Scanned with CamScanner

**៣. ចំណុចវិវាទ៖**

-ក្បាលដីលេខ១៥៦ ចុងចម្លើយអះអាងថា ជាដីរបស់ខ្លួន តែដើមចោទក៏បានអះអាងដែរថា ជាដីដែលប្ដីខ្លួនបានទិញ ។

-ចុងចម្លើយស្នើសុំលក់ដីទាំងបីកន្លែងចែកគ្នាជាបីចំណែក ដើមចោទបដិសេធ ។

## សំអាងហេតុ

- ពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ [redacted] ធី ដែលមានលោកមេធាវី [redacted], លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

- បានឃើញ ពាក្យសុំជូនពិនិត្យភស្តុតាង ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ។

- បានឃើញ ពាក្យសុំជូនពិនិត្យភស្តុតាង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ។

-បានឃើញ សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ។

-បានឃើញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៧០៨០៤០២-០៧៧៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ (ថតចម្លង)។

-បានឃើញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៧០៨០៤០២-០៧៧០ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩(ថតចម្លង)។

-បានឃើញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៧០៨០៤០២-០១៥៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩(ថតចម្លង)។

-បានឃើញកិច្ចសន្យាកក់ប្រាក់ទិញដី រវាងឈ្មោះ [redacted] សោភ័ណ្ឌ និងខ្មោចឈ្មោះ [redacted] យីស៊ុន ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ (ថតចម្លង) ។

-បានឃើញបង្កាន់ដៃដាក់ប្រាក់ ចំនួន១០៥.០០០ ( ដប់ម៉ឺនប្រាំពាន់ដុល្លារ ) របស់ធនាគារមេហ្គា ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ (ថតចម្លង) ។

-បានឃើញបង្កាន់ដៃទូទាត់ប្រាក់តាមធនាគារ អេប៊ីអេ លេខកូដប្រតិបត្តិការ៦៩៨០២២០៩០ ចំនួន៩២.៥០០ (ប្រាំបួនម៉ឺនពីរពាន់ប្រាំរយដុល្លារ) ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ (ថតចម្លង) ។

-បានឃើញ បង្កាន់ដៃដាក់ប្រាក់ចំនួន ២៤.០០០ (ពីរម៉ឺនបួនពាន់ដុល្លារ) របស់ធនាគារមេហ្គា ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ (ថតចម្លង) ។

-បានឃើញសំបុត្រអាពាហ៍ពិពាហ៍លេខ១៩ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៥ របស់ខ្មោចឈ្មោះ [redacted] យីស៊ុន និងឈ្មោះ [redacted] ធី (ថតចម្លង) ។

-បានឃើញសំបុត្រមរណភាពលេខ១៩ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ របស់ខ្មោចឈ្មោះ គីម យីស៊ុន (ថតចម្លង) ។

**តាមលទ្ធផលនៃសេចក្ដីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖**

-ដើមចោទ បានអះអាងថាប្ដីខ្លួនពិតជាបានទិញដីចំនួន ៣ កន្លែង ដែលមានទីតាំងស្ថិតនៅភូមិទ្វីខាងត្បូង សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត និងមានភស្តុតាងជាឯកសារគ្រប់គ្រាន់ដែលបានដាក់ជូនតុលាការពិនិត្យរួចរាល់ គប្បីតុលាការពិចារណា និងសម្រេច ។

-តាមកិច្ចសន្យាកក់ប្រាក់ទិញដីចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ គឺបានធ្វើឡើងរវាងខ្មោចឈ្មោះ [redacted] យីស៊ុន និងឈ្មោះ [redacted] សោភ័ណ្ឌ ដែលបានព្រមព្រៀងគ្នាក្នុងការទិញលក់ដីលើដីដែលមានទំហំក្បាលដីលេខ៧៧០ ស្ថិតនៅភូមិទ្វីខាងត្បូង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត ក្នុងតម្លៃ១១៥,០០០ដុល្លារ ដោយបានកក់មុនប្រាក់ចំនួន ១០,០០០ ដុល្លារ និងបានបង់ប្រាក់បង្គ្រប់ចំនួន ១០៥,០០០ ដុល្លារ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ពិតប្រាកដមែន ។

-តាមបង្កាន់ដៃទូទាត់ប្រាក់តាមធនាគារ [redacted] ដែលមានលេខកូដប្រតិបត្តិការ៦៩៨០២២០៩០ ចំនួន ៩២,៥០០ ដុល្លារ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ជាថ្លៃទិញដីដែលមានក្បាលដីលេខ០៧៧៧ ស្ថិតនៅភូមិទ្វីខាងត្បូង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត គឺបានកាត់ចេញពីគណនីរួមគ្នារវាងខ្មោចឈ្មោះ [redacted] យីស៊ុន និងឈ្មោះ [redacted] លីណា ផ្ទេរទៅឱ្យគណនីរបស់ម្ចាស់ដីឈ្មោះ [redacted] បូរ៉ានី ពិតប្រាកដមែន ។

-តាមបង្កាន់ដៃដាក់ប្រាក់របស់ធនាគារមេហ្គា ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ គឺបានបញ្ជាក់ថា បានដកប្រាក់ចំនួន២,៤០០ដុល្លារ ពិតប្រាកដមែន ។

-ចុងចម្លើយឈ្មោះ [redacted] លីណា បានទទួលស្គាល់ថា ដី២កន្លែងមានក្បាលដីលេខ ០៧៧៧ និង ០៧៧០ គឺខ្លួនបានចូលហ៊ុនមួយកន្លែង ២០,០០០ ( ពីរម៉ឺន ) ដុល្លារ ឯបងឈ្មោះ [redacted] សាន ចូលហ៊ុនមួយកន្លែង ៣០,០០០ ( បីម៉ឺន ) ដុល្លារ ក្រៅពីនោះគឺបងឈ្មោះ [redacted] យីស៊ុន ជាអ្នកចេញទាំងអស់ ហើយការដែលខ្លួនដាក់ឈ្មោះ តែម្នាក់ឯងនៅក្នុងប្លង់រឹង គឺដោយសារបងឈ្មោះ [redacted] យីស៊ុន ជាអ្នកឱ្យដាក់ ការអះអាងបែបនេះ មិនអាចធ្វើឱ្យតុលាការជឿជាក់បានទេ ព្រោះចុងចម្លើយ មិនមានភស្តុតាង ឬសាក្សីបញ្ជាក់ ជាពិសេសគឺពុំមានឯកសារបញ្ជាក់ពីការចូលហ៊ុន ទាំងចុងចម្លើយ ក៏ដូចជាឈ្មោះ [redacted] សាន ។

-ចំពោះក្បាលដីលេខ ០១៥៦ ចុងចម្លើយអះអាងថា ជាដីដែលខ្លួនបានទិញ តែចុងចម្លើយពុំមានឯកសារអ្វីទាំងអស់ សូម្បីតែលុយដែលត្រូវប្រគល់ឱ្យអ្នកលក់ ក៏ឈ្មោះ [redacted] យីស៊ុន ជាអ្នកប្រគល់ មួយវិញទៀតចុងចម្លើយបានទៅជាមួយអ្នកលក់ និងឈ្មោះ [redacted] យីស៊ុន ដែរ តែមិនដឹងថាបានប្រគល់លុយឬអត់ ចម្លើយដែលចុងចម្លើយបានឆ្លើយ ក៏មិនអាចឱ្យតុលាការជឿជាក់ថា ចុងចម្លើយពិតជាម្ចាស់ដីទាំងស្រុងនោះទេ ព្រោះបើចុងចម្លើយជាម្ចាស់ដីពិតប្រាកដមែន គប្បីខ្វាយខ្វល់ពីដំណាក់កាលដំបូង រហូតដល់ការប្រគល់លុយផ្សេងៗ តែចុងចម្លើយមិនដឹងអ្វីទាំងអស់ គប្បីតុលាការពិចារណា និងសម្រេច ។

-ដើមចោទបានព្រមប្រគល់ប្រាក់ចំនួន ២០,០០០ ( ពីរម៉ឺន ) ដុល្លារ ឱ្យទៅឈ្មោះ [redacted] សាន គប្បីតុលាការសម្រេច ។

-យោងតាមចម្លើយសាក្សីទាំងអស់ ក៏ដូចជាការអះអាងរបស់ចុងចម្លើយខ្លួនឯង គឺមានភាពស៊ីសង្វាក់គ្នា ត្រង់ចំណុចដែលថា ចុងចម្លើយពុំដែលដឹងពីការទិញលក់ដីទេ មានតែចូលហ៊ុនជាប្រាក់ប៉ុណ្ណោះ ដែលជាក់ស្តែងការចូលហ៊ុននេះគឺពុំមានអ្នកដឹងឮ ឬឯកសារបញ្ជាក់នោះទេ គប្បីតុលាការពិចារណា និងសម្រេច ។

-ដើមចោទស្នើសុំផ្ទេរសន្តតិកម្មរបស់មតកជនឈ្មោះ [redacted] យីស៊ុន ឱ្យទៅកូនឈ្មោះ [redacted] សូលី គប្បីតុលាការពិចារណា និងសម្រេចតាមការស្នើសុំ ដោយយោងតាមមាត្រា ១១៥៦ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

-ដើមចោទ ទាមទារឱ្យចុងចម្លើយសងសំណងជំងឺចិត្ត និងសេវាមេធាវី ចំនួន ២០,០០០ ( ពីរម៉ឺន ) ដុល្លារ គប្បីតុលាការពិចារណា និងសម្រេចតាមលទ្ធភាពជាក់ស្តែងរបស់ចុងចម្លើយ ។

-ដើមចោទជាអ្នកដាក់ពាក្យបណ្តឹង ដូច្នេះប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ធី ។



Scanned with CamScanner

# សេចក្តីសម្រេចបញ្ចប់

១)-ទទួលស្គាល់បណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ធី ដែលមានលោកមេធាវី [redacted] , លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

២)-ឲ្យចុងចម្លើយឈ្មោះ [redacted] លីណា ផ្ទេរកម្មសិទ្ធិដីចំនួនបីកន្លែង ដែលមានទីតាំងស្ថិតនៅ ភូមិទ្វីខាងត្បូង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដូចជា:

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ 07080402-0777 ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ07080402-0770 ចុះថ្ងៃទី០៦ខែធ្នូឆ្នាំ២០១៩ និង

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ 07080402-0156 ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត មកឈ្មោះ [redacted] សូលី ដែលត្រូវជាកូនស្រីបង្កើតរបស់ដើមចោទឈ្មោះ [redacted] ធី និងខ្មោចឈ្មោះ [redacted] យីស៊ុន ។

៣)-ឱ្យដើមចោទឈ្មោះ [redacted] ធី ប្រគល់ប្រាក់ចំនួន ២០,០០០ ( ពីរម៉ឺន ) ដុល្លារ ឱ្យទៅ ចុងចម្លើយឈ្មោះ [redacted] លីណា ដើម្បីឱ្យឈ្មោះ [redacted] សាន ។

៤)-ឲ្យចុងចម្លើយបង់ប្រាក់មកឲ្យដើមចោទចំនួន ២,០០០,០០០ ( ពីរលាន ) រៀល ជាប្រាក់សំណងជំងឺចិត្ត និងប្រាក់ថ្លៃសេវាមេធាវី ។ ដើមចោទទាមទារលើសពីនេះត្រូវបដិសេធចោល ។

៥)-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

-សាលក្រមនេះ ប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង២ រសៀល ចំពោះមុខដើមចោទឈ្មោះ [redacted] ធី និងចុងចម្លើយឈ្មោះ [redacted] លីណា ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

" បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃពុធ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅកំពត,ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]